[*អ្នកសម្ភាសៈ សាយ តុលា*-អ្នកផ្តល់បទសម្ភាសន៍៖ ឡាវ ម៉ិច (ឡ.ម) និង គើយ លក្ខិណា (គ.ល)]
[*Interviewer: Tola Say.* Interviewee: Lav Mech (LM) and Keuy Leakhena (KL)]

[00:00]

*ខ្ញុំចង់បង្ហាញឧបករណ៍មួយដែលគេបានរក្សាក្នុងសារៈមន្ទីរនៃចក្រភពអង់គ្លេស។ ខ្ញុំសុំឱ្យបងជួយប្រាប់ថាតើបងបានដឹងអ្វីខ្លះពីឧបករណ៍មួយនេះ? សូមបងជួយរៀបរាប់!*
*I would like to show you an instrument that has been kept in the British Museum. I want you to share what you might know about this instrument. Please kindly describe!*

គ.ល៖
KL:

គេហៅរបស់នេះថា «អង្គួច»។ អង្គួចនេះ...ពុកខ្ញុំជាអ្នកធ្វើ។ ដូចនេះហើយ ទើបខ្ញុំស្គាល់ថាវាជាអង្គួច។ ពុកខ្ញុំជាអ្នកសៀមរាប ហើយគាត់រស់នៅក្នុងភូមិព្រះដាក់។ គាត់ជាអ្នកធ្វើអង្គួចមុនគេ។ អង្គួចនេះធ្វើពីឬស្សី។ វាធ្វើដោយដៃ ហើយពុកខ្ញុំជាអ្នកធ្វើ។
This instrument is called, 'Angkuoch'. This Angkuoch... my father made it. That is why I know that it is called, 'Angkuoch'. My father is a Siem Reaper and he lived in Preah Dak village. He was the first Angkuoch maker. This type of Angkuoch is made from bamboo. It is handcrafted and my father knew how to make it.

ឡ.ម៖
LM:

ឧបករណ៍នេះជាអង្គួច។ វាជាអង្គួចធ្វើពីឬស្សី។ វាជាស្នាដៃរបស់តាគើយ។ ប្តីខ្ញុំ! គាត់ជាអ្នកធ្វើ។
This instrument is called Angkuoch. It is made from bamboo. It is a work of Ta Keuy. My husband! He was a maker.

[01:05]

*(សំណួរទៅ គ.ល) ហេតុអ្វីបានជាបងអាចដឹងថា វាជាស្នាដៃរបស់ឪពុកបង? (សំណួរទៅ ឡ.ម) ហេតុអ្វីបានជាយាយអាចដឹងថា វាជាស្នាដៃរបស់លោកប្តីយាយ?*
*(To KL:) How do you know that it is made by your father? (To LM:) And why did you say it is a work of your husband?*

គ.ល៖
KL:

ព្រោះពេលដែលខ្ញុំមើលទៅ វាដូចនឹងអង្គួចដែលគាត់ធ្វើពេលដែលគាត់នៅរស់ដែរ។ ដូចនេះបានជាខ្ញុំនិយាយថា វាជារបស់គាត់។
When I look at it, it is the same as the Angkuoch that he made when he was alive. So that is why I said it is an instrument of his.

ជាក់ស្តែង តាំងពីខ្ញុំកើតមក ខ្ញុំមិនដែលលឺអ្នកណាមួយអាចធ្វើអង្គួចក្រៅពីឪពុកខ្ញុំទេ។ មានតែពុកខ្ញុំទេដែលចេះធ្វើ! មិនដែលលឺអ្នកដទៃណាចេះធ្វើទេ! តាំងពីខ្ញុំកើតមកក្នុងអំឡុងឆ្នាំ១៩៩០។ មិនដែលឃើញអ្នកដទៃធ្វើ! ដូចនេះ វាប្រហែលជារបស់ឪពុកខ្ញុំ។
In fact, since I was born, I have never heard of any Angkuoch maker besides my father. Only my father knew how to make it. I have never heard about other makers! I was born in 1990. I have never seen other makers. Therefore, it was probably made by my father.

[01:51]

*សម្រាប់បង និងយាយ តើអ្នកទាំងពីរមានអារម្មណ៍បែបណានៅពេលដែលឃើញរូបភាពនេះ?*
*For both of you, how do you feel when you see this picture?*

ឡ.មៈ
LM:

សម្រាប់ខ្ញុំ ពេលដែលឃើញរូបភាពនេះ ខ្ញុំរំភើប និងនឹកដល់ស្នាដៃរបស់គាត់។ គាត់ចេះធ្វើ ហើយគាត់មិនដែលដឹងថាមានតម្លៃបានប៉ុណ្ណេះ។
For me, when I see this picture, I feel very excited and miss his craft. He knew how to make [Angkuoch] but he never thought it could be valued like this.

[02:18]

គ.លៈ
KL:

ពេលដែលឃើញដំបូង ខ្ញុំរំភើប។ ខ្ញុំមិនដែលនឹកស្មានថា ស្នាដៃរបស់គាត់បានផ្សព្វផ្សាយនៅថ្នាក់អន្តរជាតិ។ ដោយសារសូម្បីតែនៅក្នុងស្រុកក្មេងខ្លះមិនស្គាល់វាផង។ ដូចនេះ ខ្ញុំមិនដឹងថាវាមានតម្លៃដល់ថ្នាក់អន្តរជាតិ។ ពេលដែលឃើញអង្កួចនេះ ខ្ញុំនឹកដល់គាត់។ សម្រាប់គ្រួសារខ្ញុំ អង្កួចដូចជាតំណាងឱ្យគាត់អញ្ចឹង។ ពេលដែលឃើញអង្កួចនេះ វាដូចជាតំណាងឱ្យឪពុកខ្ញុំ។
When I saw this at first, I was very excited. I never thought his craft had been promoted on the international level. Even locally, some people do not even know about it. So I had not thought it was very valuable. Seeing this Angkuoch, I miss him. For my family, Angkuoch represents him. When I see this, it is like my father's representative.

[02:56]

*តើបងគិតថា ការរក្សាប្រពៃណីនៃការធ្វើអង្កួច និងការលេងអង្កួចមានសារៈសំខាន់ដែរឬទេ?*
*Is keeping the tradition of making and playing Angkuoch important to you?*

គ.លៈ
KL:

ខ្ញុំគិតថា វាមានសារៈសំខាន់ ដោយសារតែអង្កួចនេះជាស្នាដៃរបស់កូនខ្មែរ។ គេធ្វើវាដោយដៃផ្ទាល់។ ឧបករណ៍នេះធ្វើពីឫស្សី ហើយវាធ្វើដោយដៃផ្ទាល់។ វាជាគំនិតច្នៃប្រឌិតរបស់ខ្មែរ។ ហើយដោយសារតែគ្រួសារខ្ញុំ និងឪពុកខ្ញុំធ្វើ ខ្ញុំមានមោទកៈភាព។ មិនត្រឹមតែជាតិសាសន៍ខ្មែរជាអ្នកធ្វើទេ អ្នកដែលធ្វើនោះជាឪពុកខ្ញុំទៀត។ ខ្ញុំគិតថា វាមានសារៈសំខាន់ក្នុងការថែរក្សាវាក៏ដូចជាលើកតម្លៃរបស់វា។
I think it is very important because Angkuoch is made by Cambodians. It is a handcraft. It is made of bamboo and it is directly made by hands. It is the creativity of Khmer people. Since my father especially made it, I feel so proud. It is only Khmer who makes it, but the maker is my father. I think it is really important to preserve and promote its value.

[03:44]

*សម្រាប់យាយ តើយាយគិតយ៉ាងណាដែរ?*
*How about you, Yeay?*

ឡ.មះ
LM:

ខ្ញុំក៏គិតអញ្ចឹងដែរ។ ប្រសិនបើយើងចេះថែរក្សា ឱ្យគេស្គាល់ដល់ថ្នាក់អន្តរជាតិ។
ខ្ញុំនឹកដល់តា។ គាត់បានស្លាប់ហើយ
ហើយគាត់មិនដែលឃើញស្នាដៃគាត់ដល់ថ្នាក់នេះ។
I think that too. If you preserve and let people know about it on the international level… I miss my husband. He has passed away and he never saw his work being recognised like this.

គ.លះ
KL:

ខ្ញុំគិតថា ប្រសិនបើយើងថែរក្សា ក្មេងៗជំនាន់ក្រោយអាចស្គាល់។
នេះជាឧបករណ៍អង្គួចដែលធ្វើនៅប្រទេសខ្មែរ ហើយវាជាស្នាដៃរបស់កូនខ្មែរ។
I think if we preserve it, young people in the next generation might come to know about it. It is Angkuoch and it is made in Cambodia. It is a handicraft of the Khmer.

[04:26]

*សម្រាប់បង និងយាយ តើអ្នកទាំងពីរគិតថា*
*អនាគតរបស់អង្គួចនឹងទៅជាយ៉ាងណានៅថ្ងៃខាងមុខ?*
*For both of you, what do you think about the future of Angkuoch?*

ឡ.មះ
LM:

ដោយសារតែពិភពលោកបានទទួលស្គាល់ហើយ នៅថ្ងៃខាងមុខ
កូនខ្មែរគួរតែខិតខំរៀនធ្វើ និងធ្វើឱ្យវាខ្ពង់ខ្ពស់។
មុខរបរនេះជាមុខរបររបស់ខ្មែរសុទ្ធសាធ។ មិនមានរោងចក្រផលិតទេ! វាធ្វើដោយដៃ។
Since the world has recognised it, young people should learn to make and promote it in the near future. No manufacturer produces it. It is handmade.

គ.លះ
KL:

ខ្ញុំគិតថា ប្រសិនបើយើងគ្រប់គ្នាយកចិត្តទុកដាក់លើកតម្កើងអង្គួចនេះ
ខ្ញុំគិតថាវាពិតជាល្អ។ ហើយបងប្អូនដែលចេះធ្វើអង្គួចនេះ
ពួកគាត់ក៏អាចជួយសម្រាលបន្ទុកគ្រួសាររបស់ពួកគាត់ដែរ។ មួយវិញទៀត
វាជារបស់ជាតិយើង ហើយពួកយើងធ្វើវាដោយដៃ។
I think if we start to pay attention and promote Angkuoch, I think it would be very good. And for those who know how to make it, they can also help to reduce a family’s burden. Another thing is that it belongs to our nation and it is made by hand.

[05:25]

*ប៉ុន្តែពេលនេះ តើស្ថានភាពរបស់អង្គួចនៅក្នុងខេត្តសៀមរាបយ៉ាងម៉េចហើយ?*
*How is the situation of Angkuoch in Siem Reap currently?*

គ.លះ
KL:

វាធ្លាក់ចុះ។ អញ្ចឹងហើយបានជាខ្ញុំនិយាយថា វាអាចនឹងសាបសូន្យ។
មានមនុស្សភាគតិចណាស់ដែលគេយកអង្គួចទៅប្រកបអាជីវកម្ម។
ទីផ្សាររបស់វាមានសភាពស្ងាត់ ហើយអ្នកទិញក៏ផ្អាកទិញ។
វាជាហេតុដែលធ្វើឱ្យប៉ះពាល់ដល់អ្នកធ្វើដែរ។
ពួកខ្ញុំអ្នកធ្វើមិនដឹងថាធ្វើហើយលក់ឱ្យអ្នកណា

ហើយអ្នកលក់ក៏មិនដឹងថាលក់ឱ្យអ្នកណា។ គេមិនសូវឱ្យតម្លៃ។ ដូចនេះហើយ
វាចេះតែបន្តធ្លាក់ចុះដាលំដាប់។
It decreases. That is a reason why I say it could disappear. Only a small percentage of buyers buy Angkuoch for selling. The market does not work right and buyers also have stopped buying it. This affects the makers too. We makers do not know who to sell it to, and the buyers also do not know who to on-sell to. People do not value this instrument. So it has been decreasing dramatically.

[06:06]

*តើបងសង្ឃឹមថា វានឹងមានលក្ខណៈល្អប្រសើរនៅថ្ងៃខាងមុខទេ?*
*Do you hope that it will get better in the future?*

ក.ល៖
KL:

ខ្ញុំសង្ឃឹមថា នៅថ្ងៃអនាគតវានឹងល្អប្រសើរ
ប្រសិនបើយើងទាំងអស់គ្នាជួយលើកតម្កើង ជួយធ្វើ និងឱ្យតម្លៃទៅលើអង្កួច។
ប្រសិនបើយើងបង្វែរចំណាប់អារម្មណ៍មកចាប់អារម្មណ៍លើអង្កួច ...មិនថាតែអង្កួចទេ
ខ្លុយក៏ដោយចុះ។ ដោយសារវាជាឧបករណ៍របស់ខ្មែរយើង
ប្រសិនបើយើងងាកមកចាប់អារម្មណ៍ ខ្ញុំគិតថា វានឹងប្រសើរឡើង។
I hope that it will get better in the future if we help to promote, to make and give value to the Angkuoch. If we create interest in the Angkuoch… not only Angkuoch but also khloy [Khmer flute]. Since they are Cambodia’s instruments, if you start to pay attention to them, I think it will get better.

[06:37]

*ចុះចំណែកយាយវិញ?*
*How about you, Yeay?*

ឡ.ម៖
LM:

ខ្ញុំក៏គិតថាអញ្ចឹងដែរ។ ប្រសិនបើយើងលើកតម្កើង
ថ្ងៃក្រោយកូនខ្មែរយើងនឹងមានមុខរបរនេះតទៅទៀត។ វានឹងមិនសាបសូន្យ។
វាធ្វើដោយដៃផ្ទាល់។ វាមិនមានរោងចក្រអ្វីផលិតទេ គឺវាធ្វើដោយដៃផ្ទាល់។
I think so too. If you help to promote it, Cambodian people in the next generation would continue to make it. It will not be lost. It is a handicraft. It does not have a manufacturer to make it: it is made by hands.

[07:13]

*តើអ្នកទាំងពីរមានសារអ្វីទៅកាន់មនុស្សគ្រប់គ្នាជុំវិញពិភពលោក?*
*Do you have any message to people around the world?*

ក.ល៖
KL:

និយាយទៅម៉ែ! តើម៉ែចង់ផ្តាំផ្ញើអ្វី?
Please speak, mum! What message do you want to share?

ឡ.ម៖
LM:

ខ្ញុំសូមផ្ដាំផ្ញើឱ្យពិភពលោកទទួលស្គាល់ស្នាដៃខ្មែរក្នុងការធ្វើអង្កួចនេះ។ វាធ្វើដោយកូនខ្មែរ។ វាធ្វើដោយដៃផ្ទាល់។ ថ្ងៃមុខទៅ សូមទទួលស្គាល់ និងប្រជាជនខ្មែរប្រកបរបរអង្កួចនេះឱ្យបានធំទូលាយ។ ឱ្យពិភពលោកទទួលស្គាល់!
I would like to tell people around the world to recognise Angkuoch from Cambodia. It is made by Cambodians. It is a handicraft. Please recognise so that Cambodian people can make their Angkuoch sales bigger! Please recognise!

គ.លះ
KL:

ចុងក្រោយ ខ្ញុំក៏ចង់ផ្ដាំផ្ញើឱ្យកូនខ្មែរងាកមកស្គាល់ឧបករណ៍បុរាណខ្មែរ មិនមែនមានតែស្គរ ទ្រ និងចាប៉ីទេ តែយើងក៏មានអង្កួច។ វាក៏ជាឧបករណ៍ខ្មែរដែរ។ វាធ្វើដោយដៃ និងធ្វើដោយប្រជាជននៅក្នុងស្រុកខ្មែរ។ ប្រសិនបើយើងចង់ឱ្យប្រជាជនក្នុងស្រុក និងអន្តរជាតិ សូមងាកមកឱ្យតម្លៃអង្កួចផង។ វាធ្វើដោយដៃសុទ្ធសាធ។ ធ្វើដោយឫស្សីសុទ្ធសាធ។ អត់មានអ្វីក្រៅពីឫស្សី! សូមអ្នកគ្រប់គ្នាចាប់អារម្មណ៍លើអង្កួច!
Ultimately, I would request of all Cambodian people to think about Cambodia’s traditional musical instruments. We do not have only drum, tro [Khmer fiddle] or Chapei, but we also have Angkuoch. It is also a Khmer instrument. It is a handicraft and made by local people. If we want local people and foreigners to promote the value of Angkuoch… it is a handicraft. Just bamboo! Please start to think about Angkuoch, everyone!

*អរគុណបង!*
*Thank you!*

គ.លះ
KL:

អរគុណ!
Thanks!

*អរគុណយាយ!*
*Thanks, Yeay!*

ឡ.មះ
LM:

ចាស!
Yes!

[08:13 - END]